# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ២៦៧/០៧ គ.ជ.ប.ល.ល.វ

## សេចក្តីសម្រេច

## ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោត និងបេក្ខជនឈរឈ្មោះតំណាងរាស្ត្រ គណបក្ស សម រង្ស៊ី ចេញពីមណ្ឌលក្រុង ភ្នំពេញ

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៩ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣០៥ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- បានឃើញសេចក្តីសម្រេចលេខ ០៥.៣០៧/០៣ គ.ជ.ប. ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។
- បានឃើញសេចក្តីសម្រេចលេខ ០៨.៥១៥/០៣ គ.ជ.ប. ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៣ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ ។
- បានឃើញសេចក្តីសម្រេចលេខ ០២១ ស.ស.រ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការលុបឈ្មោះសមាជិកចេញពីបញ្ជីគណបក្ស របស់គណបក្ស សម រង្ស៊ី ។
- បានឃើញសេចក្តីសម្រេចលេខ ៧៩២.០៦/០៧ ស.ស.រ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការលុបឈ្មោះសមាជិកចេញពីបញ្ជីគណបក្ស របស់គណបក្ស សម រង្ស៊ី ។
- យោងលិខិតលេខ ១០៦.០៦/០៧ គសរ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការសុំលុបឈ្មោះ និងទទួលស្គាល់បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតគណបក្ស **សម រង្ស៊ី** មណ្ឌលក្រុង ភ្នំពេញ ។

## សម្រេច

**ប្រការ១** : លុបឈ្មោះ
១- ឯកឧត្តម **កែម សុខា** ភេទប្រុស អាយុ ៤០ ឆ្នាំ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ
២- ឯកឧត្តម **ម៉ៅ ម៉ុនីវ៉ាន់** ភេទប្រុស អាយុ ៤៩ ឆ្នាំ បេក្ខជនតំណាងរាស្ត្រ
នៃគណបក្ស **សម រង្ស៊ី** ចេញពីបញ្ជីបេក្ខជនជាប់ឆ្នោត និង បេក្ខជនឈរឈ្មោះនៅមណ្ឌលក្រុង **ភ្នំពេញ** ។

**ប្រការ២** : គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ៣** : សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៧
**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត/ប្រធាន**
**អនុប្រធាន**

ទីម សួស្តី

**ចម្លងជូនជ្រាប**
- ព្រះមហាក្សត្រ

**ចម្លងជូន**
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- បណ្ណសារដ្ឋានជាតិ
- គណបក្សនយោបាយ " ដើម្បីជូនជ្រាប "
- ដូចប្រការ២ " ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ